# ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២៧០

## ស្តីពី

## រូបសញ្ញាបច្ចេកទេស សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៥



Downloaded from http://www.khmerlaws.com

# ត្រាស់បង្គាប់

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

ត្រូវបានបង្កើតរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលបំរើការងារនៅតាមក្រសួង ស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .–**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូក ទី ២

## រូបសញ្ញាបច្ចេកទេស

**មាត្រា ៣ .–**

រូបសញ្ញាបច្ចេកទេសត្រូវបានកំណត់ដូចតទៅ ÷

- មានរាងពងក្រពើ លំអដោយពណ៌មាសសម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងពណ៌ប្រាក់សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- ទទឹងប្រវែង ១ ភាគ ២ នៃបណ្ដោយ
- នៅចំកណ្ដាល មានរូបព្រះវិស្ណុឈរលើបល្ល័ង្កលំអដោយក្បាច់ត្របកផ្កាឈូក ដែលមានព្រះហស្តបួន ។ ព្រះហស្តពីរខាងលើ ខាងឆ្វេងកាន់ខ្យងស័ង្ខ ខាងស្តាំកាន់កងចក្រ ព្រះហស្តពីរទៀតខាងក្រោម ខាងឆ្វេងកាន់ដំបងបញ្ឈរទៅក្រោម ឯខាងស្តាំកាន់ដុំមូល
- នៅអមសងខាងព្រះវិស្ណុ មាននាគមួយគូ នៅពីលើក្បាលនាគនីមួយៗ មានក្បាច់ព័ទ្ធទៅលើប្រសព្វមុខគ្នាជាកំពូលរាងជ្រលម ។

រូបសញ្ញាបច្ចេកទេសនេះ សម្រាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិចុងកអាវ និងដាក់នៅលើស័ក្តិខ្ចាស់លើអាវ បុរស ឬលើក្រមាពានារបស់នារី នៃមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ។

រូបសញ្ញាបច្ចេកទេសនេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី ១ ។

## ជំពូក ទី ៣

## សញ្ញាស័ក្តិ



Downloaded from http://www.khmerlaws.com

មាត្រា ៤ –

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមត្រូវកំណត់ដូចតទៅ ÷

## ក-ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

### ១-អំពីស័ក្តិស្មា

ស័ក្តិស្មាមានផ្ទៃកម្ពីពណ៌បៃតងចាស់ រចនាគុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅពីរមែកពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនោះ មានរូបសញ្ញាបច្ចេកទេសពណ៌មាស និងនៅពីខាងលើរូបសញ្ញាបច្ចេកទេស មានឡេវរូបព្រះសង្ខារពណ៌មាសមួយ ។ បន្ទាប់មកមានក្បាច់ផ្កាដូងមួយខ្សែពណ៌មាសព័ទ្ធជុំវិញក្នុងឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្កាដូងនេះមានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាស បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោម ÷

| | | |
|---|---|---|
| -បាតក្រោម | ប្រវែង ៦ | សង្ទីម៉ែត្រ |
| -ទទឹងមុខកាត់ផ្នែកខាងលើ | ប្រវែង ៤.៤០ | សង្ទីម៉ែត្រ |
| -បណ្តោយពីលើដល់បាតក្រោម | ប្រវែង ១៣ | សង្ទីម៉ែត្រ ។ |

### ២-អំពីស័ក្តិចុងកអាវឆនខាំងសងខាង

ស័ក្តិចុងកអាវមានផ្ទៃកម្ពីពណ៌បៃតងចាស់ រចនាគុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅពីរមែកពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញាបច្ចេកទេសពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានក្បាច់ផ្កាដូងពណ៌មាសមួយខ្សែ និងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងជាប្រលេឡូក្រាម

| | | |
|---|---|---|
| -បណ្តោយ | ប្រវែង ៩ | សង្ទីម៉ែត្រ |
| -ទទឹង | ប្រវែង ៣.៨ | សង្ទីម៉ែត្រ ។ |

### ៣-អំពីស័ក្តិចុងដៃអាវឆនខាំងសងខាង

ស័ក្តិចុងដៃអាវមានផ្ទៃកម្ពីពណ៌បៃតងចាស់ រចនាគុបតែងដោយក្បាច់ភ្ញីវល្លិប្រភេទស្លឹកព្នៅដប់មែកពណ៌មាស និងមានក្បាច់ផ្កាដូងពណ៌មាសមួយខ្សែនៅខាងលើ និងជាយផ្នែកចំហៀងសងខាង ។ ផ្ទៃខាងក្រៅ នៃក្បាច់ផ្កាដូងនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង បីខ្សែសម្រាប់សំគាល់



Downloaded from http://www.khmerlaws.com

ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។ នៅបាតក្រោមបង្អស់ នៃសញ្ញាចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយខ្សែ ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ

-ទទឹង ប្រវែង ៩ សង្ទីម៉ែត្រ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់មន្ត្រី ÷

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៣

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសម្រាប់នារី មានទំហំដូចខាងក្រោមនេះ ÷

-ចំពោះស័ក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំស័ក្តិស្មារបស់បុរសអាស្រ័យលើមាឌរបស់នារី

-ចំពោះចុងកអាវមានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣,៥ សង្ទីម៉ែត្រ អាស្រ័យលើកំពស់ករបស់នារី

-ចំពោះស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវបុរស អាស្រ័យលើមាឌរបស់នារី ។

## ៤.អំពីស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

ស័ក្តិខ្ទាស់លើអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានរាងពងក្រពើ និងកំពូលរាងជ្រលមកំពស់ ៧,៥ សង្ទីម៉ែត្រ ទទឹង ៤,៥ សង្ទីម៉ែត្រ ។ ផ្នែកខាងក្នុងមានរូបសញ្ញាបច្ចេកទេសពណ៌មាស បន្ទាប់មកមានក្បាច់ផ្កាដូងពណ៌មាសមួយព័ទ្ធអមផង ។ ផ្នែកខាងក្រោមមានខ្សែពួរវេញព័ទ្ធអមពណ៌មាស បីខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ពីរខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ និងមួយខ្សែសម្រាប់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ស័ក្តិខ្ទាស់លើអាវនេះ សម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សម្រាប់ខ្ទាស់ក្រមាពាទានារី ក្នុងឯកសណ្ឋានប្រពៃណីដែរ ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពាទាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។



Downloaded from http://www.khmerlaws.com

**ខ-ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម**

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិដូចសញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមមានពណ៌ប្រាក់ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់ ÷

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស មានដូចក្នុងឧបសម្ព័ន្ធទី ៦

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៧ និង

-ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូក ទី ៤

## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៥ -**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-ឯកសណ្ឋានផ្លូវការ**

**១-ចំពោះបុរស**

អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានគែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។

ខោកាគីជើងវែង ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២-ចំពោះស្ត្រី**

អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង ដៃវែង ត្រឹមក្អែកគោលដៃ គ្មានផែកខ្នង ។ បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន ៥ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ ចុងកអាវមានស័ក្តិ លើស្មាមានបន្ទះសម្រាប់ដាក់ស័ក្តិ គ្មានហោប៉ៅ ។

សំពត់សំឡយពណ៌កាគី មានសំរុងលើក្អែកគោលនៃស្នូងជើង ប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោម ទៅតាមមាឌ និងកំពស់របស់នារី ។

ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសម្រាប់ពេលព្រឹក ពណ៌ខ្មៅសម្រាប់ពេលល្ងាច ។ រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រី



Downloaded from http://www.khmerlaws.com

បច្ចេកទេសមធ្យម មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

**ខ-ឯកសណ្ឋានប្រពៃណីជាតិ**

**១-ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ ដៃវែងកាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផែកខ្នងអាវនេះ មានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននេះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ

-ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

**២-ចំពោះស្ត្រី**

-អាវជីបរាងពណ៌ស មានកមូល ដៃវែង រួតខ្នងបន្តិច នៅចុងអាវមានស័ក្តិ និងមានឡេវបញ្ឆោត ៣ រូបព្រះសង្ហារពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ

-ពានាក្រមាតាមពណ៌សំពត់ ឬ ពានាក្រមាពណ៌ស៊ីន្ទូន តាមពិធីការកំណត់

-នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានស័ក្តិខ្ទាស់សំគាល់ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬ មធ្យម

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ ពណ៌សសម្រាប់ពេលព្រឹក ពណ៌ខ្មៅសម្រាប់ពេលល្ងាច

-កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ (មិនអោយស្ពាយទេ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ ។

**មាត្រា ៦ .-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសមធ្យម ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការសម្រាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងពិធីការផ្សេងៗ

-ចំពោះឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណី និងសាសនាដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬ កន្លែងផ្សេងៗ ត្រូវបានកំណត់អោយប្រើឯកសណ្ឋាននេះតែមន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ។



Downloaded from http://www.khmerlaws.com

## ជំពូក ទី ៥
## របបកំណត់ឯកសណ្ឋាន និង សញ្ញាស័ក្តិ

**មាត្រា ៧ .—**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការមួយសម្រាប់ និងឯកសណ្ឋានប្រពៃណីជាតិមួយសម្រាប់ ព្រមទាំងសញ្ញាស័ក្តិ និងសម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ សម្រាប់រយៈពេលបីឆ្នាំម្តង ។

## ជំពូក ទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៨ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ .—**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

នស/រកត/០៥០៥/២៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ ២១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
**សាន់ តាន់**



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០

ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥

ស្តីពីរូបសញ្ញា [illegible] សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី

បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម



រូបសញ្ញា បច្ចេកទេស

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០៥
ស្តីពីស្លាកសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស (ពណ៌មាស)



សក្តិករអាវ



ស័ក្តិប៉ានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥
...សញ្ញាស័ក្តិ និង...
...ទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាសំគ្គិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ (ពណ៌មាស)



សំគ្គិករអាវ



សំគ្គិប៉ាន់ស្មា



សំគ្គិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ភ្ជាប់ទៅ ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០៥

# សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ (ពណ៌មាស)



សំភ្លិកអាវ



សំភ្លិចាននស្មា



សំភ្លិចុងដៃអាវ

Downloaded from http://www.khmerlaws.com

នស/រកត/០៥០៤/៧៣០

ចុះថ្ងៃទី ៧៩ ខែ ឧសភា ឆ្នាំ ២០០៤

ស្តីពីរូបសញ្ញា [illegible] សំគ្គី និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ [illegible] បខ័ណ្ឌបច្ចេកទេសមធ្យម

# សំគ្គីខ្នាស់លើអាវសម្រាប់មន្ត្រី
# នៃក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសជាន់ខ្ពស់



សម្រាប់ថ្នាក់ទន្ទះសំគ្គី
មន្ត្រីបច្ចេកទេសជាន់ខ្ពស់



សម្រាប់ថ្នាក់ទន្ទះសំគ្គី
មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ



សម្រាប់ថ្នាក់ទន្ទះសំគ្គី
មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៥
ស្តីពីរបៀបស្លៀកពាក់ឯកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែពិសេស (ពណ៌ប្រាក់)



ស័ក្តិករអាវ



ស័ក្តិបានស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ...នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី...២៩ ខែ ឧសភា ឆ្នាំ ២០០៥...
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌបច្ចេកទេសមធ្យម

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ (ពណ៌ប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ាន់ស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០

ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៥

## សញ្ញាស័ក្តិមន្ត្រីបច្ចេកទេសមធ្យម (ពណ៌ប្រាក់)



ស័ក្តិកអាវ



ស័ក្តិប៉ាតស្មា



ស័ក្តិចុងដៃអាវ

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៣០
ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌបច្ចេកទេស

## ឯកសណ្ឋានផ្លូវការ សម្រាប់បុរស និង ស្ត្រី



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី ១០ នៃប្រកាសអន្តរក្រសួងលេខ ៖ ឧសល/ប្រកស/០៥០៥/២៣០
ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៥
ស្តីពីរូបសញ្ញាបច្ចេកទេស សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី ... បរិវេណ្ឌមន្ត្រី
បច្ចេកទេសជាន់ខ្ពស់ និងក្រុមប័ណ្ឌិតបច្ចេកទេសទៀប

## ឯកសណ្ឋានប្រពៃណី សម្រាប់បុរស និង ស្ត្រី



Downloaded from http://www.khmerlaws.com